ខេមបូចា CamboJA

សមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា

Cambodian Journalists Alliance Association

(+855) 023 88 23 11

communications@camboja.net

www.camboja.net | www.cambojanews.com

# អាជ្ញាធរត្រូវប្រគល់បំណ្ណសម្គាល់អ្នកសារព័ត៌មានជូនទៅលោក អាន វិចិត្រ វិញជាបន្ទាន់

**ភ្នំពេញ ថ្ងៃទី ១៨ ខែសីហា ឆ្នាំ២០២១** – ខេមបូចាទាមទារឱ្យអាជ្ញាធរត្រូវប្រគល់បំណ្ណសម្គាល់អ្នកសារព័ត៌មានជូនទៅលោក អាន វិចិត្រ វិញជាបន្ទាន់។

លោក អាន វិចិត្រ អ្នកសារព័ត៌មានឯករាជ្យដែលកំពុងបម្រើការឱ្យខេមបូចា បានរៀបរាប់ប្រាប់ថា នៅព្រឹកថ្ងៃពុធ ទី១៨ ខែសីហានេះ លោកបានទៅស្នើសុំបំណ្ណសម្គាល់អ្នកសារព័ត៌មានរបស់លោកដែលត្រូវបានកម្លាំងអាជ្ញាធរខណ្ឌមានជ័យ ដកហូតយកកាលពីព្រឹកថ្ងៃសុក្រ ទី១៣ ខែសីហា ក្នុងពេលលោកចុះយកព័ត៌មានពីជម្លោះដីធ្លីរវាងពលរដ្ឋ និងអាជ្ញាធរនៅតំបន់បឹងទំពុននោះមកវិញ ប៉ុន្តែត្រូវបានមន្ត្រីសាលាខណ្ឌ និងមន្ត្រីប៉ូលីសនៅអធិការនគរបាលខណ្ឌឆ្លើយបដិសេធថា មិនបានដកហូតយកបណ្ណសម្គាល់អ្នកសារព័ត៌មានរបស់លោកទេ។

លោក អាន វិចិត្រ បញ្ជាក់ថា ដំបូង លោកទៅសាលាខណ្ឌ ប៉ុន្តែត្រូវមន្ត្រីនៅទីនោះប្រាប់ឲ្យទៅសួរនៅអធិការដ្ឋាននគរបាលខណ្ឌមានជ័យ។ ពេលលោកទៅដល់អធិការដ្ឋាននគរបាលខណ្ឌ លោកបានសួរមន្ត្រីប៉ូលីសម្នាក់នៅទីនោះ ដោយបានរៀបរាប់ពីគោលបំណងរបស់លោក និងដំណើររឿងហេតុ តែមន្ត្រីប៉ូលីសរូបនោះប្រាប់គាត់ឲ្យទៅសួរមេរបស់គាត់។ នៅពេលលោក អាន វិចិត្រ ទៅសួរមេរូបនោះ ឆ្លើយថា «អត់ដឹង» ហើយបានប្រាប់ឲ្យទៅសួរនៅប៉ុស្តិ៍នគរបាលសង្កាត់បឹងទំពន់ទី១។ ពេលលោកទៅសួរនៅប៉ុស្តិ៍នគរបាលបឹងទំពន់ទី១ មន្ត្រីប៉ូលីសប៉ុស្តិ៍ក៏ឆ្លើយថា «មិនដឹង ព្រោះមិនបានដកកាតព័ត៌មានអ្វីទេ»។

កាលពីព្រឹកថ្ងៃសុក្រ ទី១៣ ខែសីហា កម្លាំងសមត្ថកិច្ចអាជ្ញាធរខណ្ឌមានជ័យបានដកហូតបំណ្ណសម្គាល់ខ្លួនអ្នកសារព័ត៌មានរបស់លោក អាន វិចិត្រ ហើយបង្ខំឲ្យលោក និងអ្នកសារព័ត៌មានដែលជាសមាជិកខេមបូចាម្នាក់ទៀត លុបរូបភាព និងវីដេអូអំពីការតវ៉ារបស់ក្រុមប្រជាពលរដ្ឋក្នុងពេលកម្លាំងសមត្ថកិច្ចចម្រុះខណ្ឌមានជ័យចុះរុះរើលំនៅស្ថានរបស់ពលរដ្ឋនៅតំបន់បឹងទំពន់។ សមត្ថកិច្ចថែមទាំងបានគំរាមរូបលោកថា ប្រសិនបើលោកមិនព្រមលុបរូបចោលទាំងអស់នៅចំពោះមុខសមត្ថកិច្ចទេ លោកនឹងត្រូវប្រឈមនឹងការឃាត់ខ្លួន។ ទោះបីជាលោក អាន វិចិត្រ ព្យាយាមបញ្ជាក់ប្រាប់ថា លោកជាអ្នកសារព័ត៌មានដោយបានបង្ហាញកាតអ្នកសារព័ត៌មានជូនសមត្ថកិច្ចយ៉ាងណាក៏ដោយ ក៏សមត្ថកិច្ចនៅតែបង្ខំឲ្យលោកលុបរូបទាំងអស់ចេញពីកាមេរ៉ារបស់លោក ហើយថែម

(+855) 023 88 23 11
communications@camboja.net
www.camboja.net | www.cambojanews.com

ទាំងបានដកហូតកាតសារព័ត៌មានរបស់គាត់យកទៅបាត់។ ទោះលោកព្យាយាមស្នើសុំវិញយ៉ាងណា ក៏សមត្ថកិច្ច នៅតែមិនព្រមប្រគល់មកឲ្យវិញ ដោយប្រាប់ថា ឱ្យលោកទៅយកនៅសាលាខណ្ឌ។

លោក អាន វិចិត្រ សម្តែងនូវការខកចិត្តយ៉ាងខ្លាំងចំពោះទង្វើរបស់អាជ្ញាធរខណ្ឌមានជ័យ ដែលមិនបង្ហាញការទទួលខុសត្រូវរបស់ខ្លួន។

ខេមបូចាទទូចទាមទារដល់អាជ្ញាធរត្រូវប្រគល់បំណ្ណសម្គាល់អ្នកសារព័ត៌មានជូនទៅលោក អាន វិចិត្រ វិញភ្លាមៗ ហើយបង្ហាញការទទួលខុសត្រូវចំពោះទង្វើរំលោភសិទ្ធិអ្នកសារព័ត៌មាន៕

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

**លោក ណុប វី**
នាយកប្រតិបត្តិ
០១២ ៥១៩ ២៦១
ed@camboja.net

**លោក ហ៊ីម ខទៀត**
មន្ត្រីគ្រប់គ្រងកម្មវិធីស្រាវជ្រាវ និង តស៊ូមតិ
០១៦ ៥៧៥ ៧១៣
khortieth.him@camboja.net

# CamboJA demands immediate return of confiscated press card to An Vichet

**Phnom Penh, August 18, 2021** – The Cambodian Journalists Alliance Association (CamboJA) urges Meanchey District authority to immediately return the confiscated press ID card to Mr. An Vichet.

An Vichet, freelance journalist working for CamboJA, said he went to Meanchey district office and the district police office this morning to ask for the return of his press card, which was confiscated by the district authority on August 13 while covering a land dispute between authorities and residents along Boeng Tompun lake, but both district officials and district police officers denied knowing about the case.

Mr. An Vichet said he first went to the district hall where he was told to go to the district police station. When he arrived at the district police station, he talked to a police officer there by explaining his intention and the story background. The officer then told Vichet to talk to his boss who said he did not know about this case and referred Vichet to Boeung Tumpun I commune police station. When he arrived at Boeung Tumpun I police station, the police officer told Vichet "he did not know about the case and said no press card was confiscated."

On Friday 13th August, Meanchey district authorities confiscated the press identification card of An Vichet and forced him as well as the other CamboJA's member Lors Lib Lib to delete all of their pictures and videos of villagers protesting against joint police force of Meanchey district who were demolishing their houses along Boeung Tumpun lake. An Vichet told CamboJA that the authorities even threatened him of arrest if he refused to remove all the images in front of them. Although he tried to prove that he was a journalist by presenting the press card, they still forced him to delete all the pictures from his camera and even confiscated his press card. The authorities still refused to return the press card to him, regardless of his explanation, and referred him to take the card at the district office.

Mr. An Vichet expressed his disappointment with the Meanchey distric authority for showing no responsibility for their actions.

CamboJA insists the authority must immediately return the press card to An Vichet and take responsibility for its abusive actions against media rights.

**For more details please contact:**
**Mr. Nop Vy, Executive Director**
**012 519 261 | ed@camboja.net**

**Mr. Him Khortieth, Research & Advocacy Manager**
**016 575 713 | khortieth.him@camboja.net**